ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ១០/១៤ ប.ស.ស

# សេចក្តីជូនដំណឹង
# ស្តីពីនីតិវិធីនៃការបង់ភាគទាន

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សូមជូនដំណឹងចំពោះគ្រប់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានចុះបញ្ជីកាក្នុងបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានជ្រាបថា ដើម្បីសម្រួលដល់ដំណើរការនៃការបង់ភាគទាន ប.ស.ស សូមធ្វើការណែនាំដូចខាងក្រោម ៖

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីបេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់ ។ ការបង់ភាគទានអាចត្រូវបានអនុវត្តតាមរបៀបដូចខាងក្រោម ៖

១- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់ផ្ទាល់នៅធនាគារដូចមុនដដែល ឬ

២- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់តាមរយៈសេវាកម្មអ៊ិនធើណែតបែងឃីង (Internet Banking) ឬ សេវាកម្មយូនីធី (Unity) ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ តទៅ ។ រាល់ការចំណាយសេវាកម្មនេះជាបន្ទុកផ្ទាល់របស់និយោជក ។

៣- ចំពោះបង្កាន់ដៃបង់ភាគទាន របាយការណ៍ចំនួនកម្មករនិយោជិត របាយការណ៍ប្រាក់ឈ្នួល ឬ ឯកសារចាំបាច់នានា និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកមកដាក់ដោយផ្ទាល់នៅការិយាល័យ ប.ស.ស ឬ ផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬ ផ្ញើតាមសារអេឡិចត្រូនិច contribution@nssf.gov.kh ។

*បញ្ជាក់ ៖*

ចំពោះលោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទានរួចហើយ ផ្ញើរបាយការណ៍កម្មករនិយោជិតតាមរយៈសារអេឡិចត្រូនិច ត្រូវមានឯកសារដូចជា ៖

- របាយការណ៍កម្មករនិយោជិត (ទម្រង់អេឡិចត្រូនិច E-Form)
- លិខិតប្រកាសបង់ភាគទានហានិភ័យការងារ
- លិខិតបញ្ជាក់ពីនិយោជក (Form B)
- តារាងបើកប្រាក់បៀវត្សកម្មករ និយោជិត (ទម្រង់អេឡិចត្រូនិច Payroll)

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ទាំងអស់ នឹងចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះជាក់ជាពុំខាន ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤